# គួរវ៉ាកងធំ  វគ្គទីមួយ

ពីរបីថ្ងៃបន្ទាប់ពីឆមាសចប់សព្វគ្រប់អស់ហើយ បុប្ផា និងរិទ្ធិ ទៅលេងផ្ទះសម្ផស្ស ។ ពេលនោះសម្ផស្សកំពុងតែរវល់ធ្វើនំ នៅក្នុងចង្ក្រានបាយ ជាមួយម្ដាយនាង ដែលជាអ្នកយកនំទៅចែកលក់នៅផ្សាររាល់ថ្ងៃ ។ សម្ផស្សនិយាយទាំងញញឹមនៅកាន់មិត្តទាំងពីរថា:

- អ៊ុំ! ពួកឯងមកផ្ទះគ្នា ដើម្បីរកនំញ៉ាំ មែនទេ?
- ឯងស្មានតែគ្នាមកលេងឯងទទេៗហ្អេ៎? (បុប្ផាឆ្លើយ)
- ខ្ញុំដឹងមុនបាត់ទៅហើយ (សម្ផស្សនិយាយបែបលេង) ។ បាន... បើពីរនាក់ឯងចង់ញ៉ាំពួកឯងត្រូវតែជួយគ្នាធ្វើនំសិន ។

បុប្ផា និងរិទ្ធិ ក៏ជួយសម្ផស្ស និងម្ដាយនាងធ្វើនំ ។ នំទាំងនោះឈ្ងុយរហូតធ្វើអោយពួកគេឃ្លានស្ទើរស្រក់ទឹកមាត់ទៅហើយ ។ បន្តិចក្រោយមក ម្ដាយសម្ផស្សក៏និយាយថា:

- មើលនំទាំងនេះផង ម៉ែទៅយកម្សៅមកថែមទៀតសិន!
- ហ៉េ...រិទ្ធិ! (បុប្ផាសួរទៅរិទ្ធិ) ពេលណាទើបឯងចុះឈ្មោះចូលរៀនគួរវ៉ាកង?
- គ្នាបានចុះឈ្មោះរួចហើយ (រិទ្ធិតបទៅវិញ) ហើយបានចុះឈ្មោះអោយដានីទៀតផងហ្ន៎ ។
- អូ...ហូ... (សម្ផស្សនិយាយទាំងញញឹមផង) ឯងនឹងបានអង្គុយជាប់នាងហើយអ៊ីចឹង?
- ហេតុអ្វីឯងចុះឈ្មោះមុនពួកយើង? (បុប្ផានិយាយទាំងខឹងបន្តិច) ក្រែងយើងធ្លាប់តែអង្គុយតុជាមួយគ្នារហូតមកហ្អេ៎ ។
- សម្ផស្ស យើងគិតរកចុះឈ្មោះជាមួយគ្នាហ្អេ៎? ធ្វើអ៊ីចឹងទើបយើងបានអង្គុយជាប់គ្នា (បុប្ផានិយាយបែបចំអកទៅរិទ្ធិ) ។



បុប្ផាបាចមេឡៀដាក់រិទ្ធ ហើយនិយាយថាៈ

- លើកក្រោយចុះឈ្មោះ ចាំពួកយើងផង!

រិទ្ធក៏បាចមេឡៀត្រឡប់ទៅបុប្ផាវិញ ។ ឃើញដូច្នេះ សម្ផស្សមិនអាចទ្រាំបាន ក៏ចូលរួមបាចមេឡៀលេងជាមួយពួកគេដែរ ។ រំពេចនោះ ម្តាយសម្ផស្សក៏ត្រឡប់មកវិញ ឃើញមុខពួកគេប្រឡាក់មេឡៀសពេញមុខ ក៏ស្តីអោយៈ

- ម៉េចពួកឯងហ៊ានលេងអីផ្តេសផ្តាសអីចឹង? ពួកឯងដឹងទេថាកសិករធ្វើការដាំដុះលំបាកប៉ុនណាទម្រាំបានអង្ករនេះឡើង ។ មីងធ្លាប់ធ្វើស្រែ មីងដឹង ។ បើពួកឯងមិនគោរពមេឡៀអង្ករនេះទេ មានន័យថាពួកឯងមិនគោរពកសិករដែលធ្វើការយ៉ាងលំបាកនៅវាលស្រែនោះទេ ។

រិទ្ធ និង បុប្ផាដឹងខុស ហើយក៏និយាយសុំទោសៈ

- ពួកខ្ញុំសុំទោសមីង ។

- ម៉ែកូនសុំទោសផង (សម្ផស្សសុំទោសម្តាយនាង) ។

ពួកគេក៏បន្តធ្វើនំតទៅទៀត ។

បុប្ផានិយាយពីផែនការរបស់នាងបន្តទៀតៈ

- បើសិនជាខ្ញុំមានពេល ខ្ញុំចង់ហាត់ការ៉ាតេដែរ! គិតថាល្អហ្អេ? ថ្ងៃណាមួយ ខ្ញុំប្រហែលអាចក្លាយជាតារាភាពយន្ត ផងក៏មិនដឹង ។ សម្ផស្ស ចង់ទៅហាត់ជាមួយខ្ញុំហ្អេ?

សម្ផស្សដកដង្ហើមធំ ។ រឿងលុយកាក់គឺជាបញ្ហាមួយរបស់គ្រួសារនាង ។ នាងឆ្លើយៈ

- គ្នាមិនដឹងទេ ។ ចាំគ្នាសួរម៉ែសិន ។

បន្ទាប់ពីបាយថ្ងៃត្រង់រួច ពួកគេទាំងបីនាក់អង្គុយខាងក្រៅញុំានំ ។

- ពួកយើងគួរតែត្រលប់ទៅផ្ទះវិញហើយ (រិទ្ធិនិយាយ) ។

ពេលនោះសម្ផស្សក៏ឆ្លើយតបវិញថាៈ

- អីចឹងក៏បាន អរគុណពួកឯងហើយណ៎ា ថ្ងៃនេះ ។

- សម្ផស្ស! (បុប្ផានិយាយ) ថ្ងៃស្អែក ឯងទៅចុះឈ្មោះរៀនគួរ៉ាកងជាមួយគ្នាហ្អេ? ចាំគ្នាមកយកឯង ។

សម្ផស្សឆ្លើយ

- អឺ... អឺ... គ្នាត្រូវសួរម៉ែសិន ។ ឯងចាំគ្នាខានស្អែកបានហ្អេ?

- បានតើ...មានអី ។

បុប្ផា និងរិទ្ធក៏ចាកចេញទៅ ។ សម្ផស្សគិតក្នុងចិត្តថា : សង្ឃឹមថាម៉ែអាចបង់ថ្លៃគួរ៉ាកងអោយខ្ញុំបានទៅចុះ ។

ថ្ងៃបន្ទាប់មកទៀតនាពេលព្រលឹមស្រាងៗ សម្ផស្សនិងម្តាយជិះម៉ូតូដឹកនំយកទៅដាក់តាមហាងនានា ។ ពួកគេត្រូវធ្វើការងារដ៏ហត់នឿយនេះពេញមួយព្រឹក តែបានសម្ផស្សជួយបែបនេះ វាលឿន ហើយងាយស្រួលបន្តិចដែរ ។ ម្តាយសម្ផស្សក៏បានប្រមូលលុយពីការលក់នៅសប្តាហ៍នេះផងដែរ ។



សម្ផស្សសួរម្តាយនាងថា ៖

- ម៉ែហ្នា... ឆ្នាំក្រោយ ខ្ញុំចូលរៀនថ្នាក់ទី១២ហើយ ។ ម៉ែគិតថា កូនគួរតែរៀនគួរវ៉ាកង សម្រាប់ត្រៀមថ្នាក់ដ៏សំខាន់នេះដែរទេ ម៉ែ?

ម្តាយសម្ផស្សឆ្លើយដោយញញឹមថា ៖

- ប្រាកដហើយ តែ... យើងត្រូវតែយកនំដែលនៅសល់ទាំងនេះ ទៅលក់នៅផ្សារចាស់ នៅពេលរសៀលនេះ និងប្រមូលលុយពីអ្នកលក់សិន ទើបកូនមានលុយគ្រប់សម្រាប់បង់ថ្លៃរៀនគួរ ។

- មិនបាច់ព្រួយអីទេ ម៉ែ ។ ខ្ញុំនឹងយកវាទៅលក់ រសៀលនេះ (សម្ផស្សនិយាយ) ។

- អ៊ីចឹងក៏បាន (ម្តាយនាងញញឹមម្តងទៀត) ។

បន្ទាប់ពីបាយថ្ងៃត្រង់រួច សម្ផស្សរួតរះរៀបចំធ្វើដំណើរទៅផ្សារចាស់ ។

- សុំទោសផង ក្មួយសម្ផស្ស (ស្ត្រីចំណាស់ម្នាក់និយាយ) ។ ខែនេះ មីងត្រូវបង់លុយក្រៅអោយគេច្រើនណាស់ ។

- គេតម្លើងពន្ធ ឬមីង? (សម្ផស្សសួរទាំងងឿងឆ្ងល់)

- ទេ មិនមែនអ៊ីចឹងទេ ធ្វើជាអ្នកលក់ដូរ ក្មួយអើយ... យើងត្រូវចេះបត់បែនតាមកាលៈទេសៈ ។ មីងត្រូវបង់ថ្លៃអារឿងក្រៅផ្លូវការនោះច្រើនណាស់ ។ ធ្វើជាអ្នកលក់ដូរ គឺធ្វើបែបនេះឯង ។ ទើបតឡូវ មីងមិនអាចសងលុយឯងសម្រាប់ថ្លៃនំកាលពីអាទិត្យមុនបានទេ ។

សម្ផស្សបន្តដើរទារលុយតាមតូបផ្សេងៗទៀត ។ ម្នាក់ៗនិយាយរឿងស្រដៀងៗគ្នា ។

- មីងសុំទោស មីងមិនអាចសងឯងបានទេ ព្រោះស្អីៗគ្រប់យ៉ាងឡើងថ្លៃ ។ ឯងបញ្ចុះថ្លៃនំឯងបានទេ?

- អរគុណ ដែលយកនំមកអោយ ចាំអាទិត្យក្រោយ ចាំមីងអោយលុយ ។

- ពូសុំទោសក្មួយផង ពូត្រូវបង់ថ្លៃអ្វីផ្សេងទៀតបន្ថែមច្រើនណាស់ ។

- សុំទោសព្រោះចំណាយខ្ញុំតឡូវកើនឡើងច្រើនពេក ។

បន្ទាប់ពីដើរបោះនំតាមតូបរួចមក សម្ផស្សអង្គុយនៅតូបលក់ ទឹកអំពៅហើយក៏បានផឹកទឹកអំពៅដើម្បីសម្រាក ។ បន្ទាប់មកនាង រាប់លុយ ។

- បានតិចជាងរាល់ដងឆ្ងាយណាស់ ។

រឿងនេះធ្វើអោយនាងពិបាកចិត្តយ៉ាងខ្លាំង ។ តើនាងគួរប្រាប់ម្តាយនាងថាយ៉ាងណា? នេះអាចជាបញ្ហាធំសម្រាប់គ្រួសារនាង ។



*រៀនគួរ! ហ៊ឺ...វាដូចជានៅឆ្ងាយពីនាងសម្ញើមណាស់នៅពេលនេះ។*
*តើនាងគួរនិយាយប្រាប់គ្រួសារនាងថាដូចម្តេចទៅ?*
*តើនាងត្រូវនិយាយប្រាប់មិត្តនាងថាដូចម្តេច?*
*សម្ផស្សពិបាកចិត្តណាស់ ហើយដូចជាមានអារម្មណ៍ពិបាកនឹងប្រឈមមុខនឹងបញ្ហាទាំងនេះណាស់។ នាងអង្គុយនៅតូបលក់ទឹកអំពៅយ៉ាងយូរសញ្ជឹងគិតពី តើត្រូវធ្វើយ៉ាងណា ដើម្បីប្រឈមនឹងបញ្ហាចំពោះមុខនេះ។*

**សូមសរសេរសាច់រឿងបន្តរបស់ខត្ត "គួរទាក់ទង" ខាងលើនេះ**
**ហើយផ្ញើមកកាន់: អង្គការ សៀវភៅយើង**

លោកអ្នកក៏អាចផ្ញើសំបុត្រតាមរយៈការិយាល័យប្រចាំខេត្ត
របស់អង្គការខាងក្រោម:

អង្គការយុវជនខ្មែរ និងអភិវឌ្ឍសង្គម (KYSD)
អាសយដ្ឋាន : ផ្ទះលេខ1BEo ផ្លូវ338 សង្កាត់ទួលស្វាយព្រៃ1
ខណ្ឌចំការមន រាជធានីភ្នំពេញ។ ទូរស័ព្ទ : 012 798 488

មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP)
អាសយដ្ឋាន : ផ្ទះលេខ135A ផ្លូវ259 សង្កាត់ទឹកល្អក់1 ខណ្ឌទួលគោក
រាជធានីភ្នំពេញ។ ទូរស័ព្ទ : 016 828 211




**ឧបត្ថម្ភដោយ**

USAID FROM THE AMERICAN PEOPLE
Pact Cambodia BUILDING CAPACITY WORLDWIDE
DANIDA
PADCO | AECOM

សៀវភៅនេះ បានបោះពុម្ពផ្សាយឡើងដោយមានជំនួយសប្បុរសធមិរបស់ប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៏អន្តរជាតិ និងប្រជាពលរដ្ឋដាណឺម៉ាក តាមរយៈទីភ្នាក់ងារដាណឺម៉ាកសំរាប់ការអភិវឌ្ឍន៏អន្តរជាតិ ។ ខ្លឹមសានៅក្នុងសៀវភៅនេះ ជាការទទួលខុសត្រូវរបស់ អង្គការសៀវភៅយើង (OUR BOOKS) ហើយមិនឆ្លុះបញ្ចាំងទស្សនៈរបស់ USAID DANIDA ឬ PACT ឬ PADCO ទេ។

សៀវភៅយើង SON LIVRES OUR BOOKS

© **សៀវភៅយើង** 2006

ផ្ទះលេខ 32 ផ្លូវលេខ 184
ខណ្ឌឫស្សីកែវ
ប្រអប់សំបុត្រ 988
ភ្នំពេញ - កម្ពុជា
ទូរស័ព្ទ : 855-23 223 242
choices@siewphewyeung.org.kh
www.siewphewyeung.org.kh

រាល់ការចម្លងទាំងអស់ ឬការចម្លងផ្នែកណាមួយនៃសៀវភៅនេះ ទោះបីជាតាមរបៀបណាក៏ដោយដោយគ្មានការយល់ព្រមពីអង្គការ **សៀវភៅយើង** គឺខុសច្បាប់ និងត្រូវមានទោស ។ រក្សាសិទ្ធិចំលង និងបកប្រែចំពោះគ្រប់ភាសាទាំងអស់

បោះពុម្ពនៅប្រទេសកម្ពុជា
ដោយរោងពុម្ព
3DGraphics Publishing

ISBN: 99950-853-1-3
9789995085315

រឿង **ជំរើសជីវិត**



សម្ផស្ស បុប្ផ និងរិទ្ធិ ជាមិត្តស្និទ្ធស្នាលនឹងគ្នា តាំងពីកុមារភាព។ ឆ្នាំសិក្សាថ្មីនេះ មិត្តទាំងបីនាក់រៀនជាមួយគ្នានៅថ្នាក់ទី១១ងនៃវិទ្យាល័យកំពង់ស្ពាន។ នៅក្នុងថ្នាក់រៀន មានសិស្សស្រីម្នាក់ស្អាតឈ្មោះដានី។ សិស្សប្រុសមួយណាក៏ចាប់ចិត្តប្រតិព័ទ្ធលើរូបនាងដែរ។ នៅក្នុងចំណោមសិស្សប្រុសទាំងអស់នោះក៏មានរិទ្ធិម្នាក់ដែរ។ ដានីមិនត្រឹមតែស្អាតទេ នាងថែមទាំងក្លាហានហើយឧស្សាហ៍ព្យាយាមទៀត។ ខុសពីរិទ្ធិ ដែលជាមនុស្សអៀនប្រៀនច្រើន ហើយមិនសូវក្លាហានទៀត ។ គូប្រកួតប្រជែងមានច្រើន តើរិទ្ធិត្រូវធ្វើ យ៉ាងណាដើម្បីអោយដានីចាប់អារម្មណ៍លើរូបគេ?

សម្ផស្សមានរូបមន្តពិសេសម្យ៉ាងអាចជួយអោយមិត្តសម្លាញ់របស់នាងសមតាមបំណង។ តើរូបមន្តពិសេសសម្រាប់យកឈ្នះលើចិត្តស្រីស្អាតនោះជាអ្វីទៅ?